**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ថវិកាពលរដ្ឋ ២០២៥

Citizen Budget

Fiscal Year 2025

## ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

Ministry of Industry, Science, Technology & Innovation




អាស័យដ្ឋាន ៖ ៤៥ មហាវិថីព្រះនរោត្តម សង្កាត់ ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ ៖ ០២៣ ២១១១៤១

គេហទំព័រ ៖ https://www.misti.gov


## ១- ចក្ខុវិស័យ និងបេសកកម្មចម្បងៗ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការដឹកនាំ និងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងនឹងបន្តអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា បន្តធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម តាមរយៈការជំរុញលើកទឹកចិត្តការវិនិយោគក្នុងវិស័យឧស្សាហកម្មថ្មីៗ ទំនើបប្រកបដោយគុណភាព សោភ័ណភាព និងមានតម្លៃបន្ថែមខ្ពស់ មានភាពច្នៃប្រឌិតរស់រវើក និងមានសមត្ថភាពប្រកួតប្រជែងនៅក្នុងទីផ្សារជាតិ និងអន្តរជាតិ ពិសេសឧស្សាហកម្មផ្គុំដំឡើង ឧស្សាហកម្មអេឡិចត្រូនិច ឧស្សាហកម្មគ្រឿងបន្លាស់ ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកម្មន្តសាល ផ្សេងទៀត គួបផ្សំនឹងការបន្តជំរុញការអភិវឌ្ឍសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យទៅដល់ទីជនបទ និងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន ព្រមទាំងបំពេញនូវបេសកកម្មថ្មីដែលរាជរដ្ឋាភិបាលប្រគល់ជូនក្នុងការបង្កើតជំរុញការអភិវឌ្ឍ និងការសិក្សាស្រាវជ្រាវលើការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ បង្កើនចំណូល និងលើកកម្ពស់សុខុមាលភាពប្រជាជន។

ផ្អែកតាមអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានមុខងារ និងភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមរបស់រាជរដ្ឋាភិបាល ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្មនិងទឹកស្អាត
- ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការអភិវឌ្ឍក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត
- ដឹកនាំ និងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងសិប្បកម្ម និងទឹកស្អាតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំគោលនយោបាយនិងកម្មវិធីអភិវឌ្ឍរោងចក្រ សហគ្រាសធុនតូចនិងមធ្យម សិប្បកម្មនិងទឹកស្អាត
- សម្របសម្រួល សហការ និងអនុវត្តការងារសិក្សាស្រាវជ្រាវពិសោធន៍ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ នវានុវត្តន៍ ដើម្បីគាំទ្រនិងជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត
- ជំរុញ និងគាំទ្រនវានុវត្តន៍បច្ចេកវិទ្យា តក្កកម្ម គ្រប់គំនិតផ្តួចផ្តើមថ្មីៗ រួមទាំងសហគ្រិនភាពក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត
- គ្រប់គ្រង វាយតម្លៃ ទទួលស្គាល់ និងផ្តល់វិញ្ញាបនបត្រ ប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយបច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំ គ្រប់គ្រង និងផ្សព្វផ្សាយការងារស្តង់ដារូបនីយកម្ម និងការធានាគុណភាពផលិតផល
- ធ្វើជាអាណាព្យាបាលបច្ចេកទេសលើសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវ បានបង្កើតឡើងនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយការងារមាត្រាសាស្ត្រ
- រៀបចំ គ្រប់គ្រង និងអនុវត្តនយោបាយផ្គត់ផ្គង់ទឹកស្អាតដល់ទីក្រុង និងទីប្រជុំជន
- សហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ ស្ថាប័ន អង្គការជាតិនិងអន្តរជាតិនានា រួមទាំងវិស័យ ឯកជន ដើម្បីជំរុញអភិវឌ្ឍន៍វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត។

## ២- គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ២០២៥

ដើម្បីសម្រេចបានជោគជ័យ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានកំណត់គោលដៅសូចនាករក្នុងឆ្នាំ ២០២៥ ដូចខាងក្រោម ៖

| គោលបំណងកម្មវិធី | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ) |
|---|---|---|
| កម្មវិធីទី១៖ ការគ្រប់គ្រងនិងអភិវឌ្ឍវិស័យទឹស្អាត | សូចនាករទី១៖ ចំនួនតំណភ្ជាប់បណ្តាញទឹកស្អាតថ្មី | ៨០ ០០០ តំណ |

| | | |
|---|---|---|
| កម្មវិធីទី២៖ ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសិប្បកម្ម ផ្នែកកម្មន្តសាល និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ | សូចនាករទី១៖ ចំនួនរោងចក្របង្កើតថ្មី | ២២០ រោងចក្រ |
| | សូចនាករទី២៖ ចំនួនសហគ្រាសធុនតូច មធ្យមនិងសិប្បកម្មថ្មី ដែលទទួលបានការចុះបញ្ជី | ១ ៥៥០ មូលដ្ឋានផលិតកម្ម |
| | សូចនាករទី៣៖ ចំនួនវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់បញ្ជាក់សមត្ថភាព និងវិញ្ញាបនបត្រចុះបញ្ជី ត្រូវផ្តល់ជូនអង្គភាពវាយតម្លៃភាពអនុលោម និងលិខិតអនុញ្ញាតផ្តល់ជូនអង្គភាពវាយតម្លៃទទួលស្គាល់ក្រៅប្រទេស | ១០ វិញ្ញាបនបត្រ , ៤ លិខិតអនុញ្ញាត |
| | សូចនាករទី៤៖ ចំនួនស្តង់ដារថ្មី និងកែសម្រួល | ៥០ ស្តង់ដារ ៖ -៤ ស្តង់ដារក្នុងស្រុក -៤១ ការទទួលស្តង់ដារអន្តរជាតិធ្វើជាស្តង់ដារជាតិ -៥ កែសម្រួល |
| | សូចនាករទី៥៖ ចំនួនឧបករណ៍មាត្រាសាស្ត្រ ដែលត្រូវធ្វើព្យាសកម្ម ត្រួតពិនិត្យផ្ទៀងផ្ទាត់ និងសេវាមាត្រាសាស្ត្រ | ៣ ១១២ គ្រឿង ៖ -ព្យាសកម្ម ១ ១០០ គ្រឿង, -ត្រួតពិនិត្យផ្ទៀងផ្ទាត់ ១ ០៥៥ គ្រឿង/មុខ -សេវាមាត្រាសាស្ត្រ ៩៥៧ សេវា |
| | សូចនាករទី៦៖ ចំនួនសំណាកត្រូវធ្វើតេស្តវិភាគ | ១៣ ៩០០ សំណាក |
| កម្មវិធីទី៣៖ ការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សូចនាករទី១៖ របាយការណ៍បច្ចុប្បន្នភាពស្តីពីការអនុវត្តគោលនយោបាយសម្រាប់ការអភិវឌ្ឍវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១ របាយការណ៍ត្រូវបានរៀបចំ |
| | សូចនាករទី២៖ ចំនួនសហគ្រាសធុនតូចនិងមធ្យម ត្រូវបានផ្តល់ដំណោះស្រាយបច្ចេកទេសដោយប្រើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ១០ មូលដ្ឋានផលិតកម្ម |
| កម្មវិធីទី៤៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | សូចនាករទី១៖ ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង | ត្រូវបានពង្រឹង |
| | សូចនាករទី២៖ សេវាគាំទ្រទូទៅផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ | ត្រូវបានធានា និងទាន់ពេល |

## ៣- ថវិកាឆ្នាំ២០២៥

ក្នុងការសម្រេចឱ្យបាននូវគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករខាងលើ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានទទួលឥណទានក្របខណ្ឌថវិកាជាតិឆ្នាំ២០២៥ សរុបចំនួន ៥៨,៦៧១.០ លានរៀល ទៅតាមកម្មវិធី និងអនុកម្មវិធីនីមួយៗដូចខាងក្រោម ៖

- ➢ កម្មវិធីទី១៖ ការគ្រប់គ្រងនិងអភិវឌ្ឍវិស័យទីស្អាត ចំនួន ៨៦០.២ លានរៀល
- ➢ កម្មវិធីទី២ ៖ ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសិប្បកម្ម ផ្នែកកម្មន្តសាល និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ចំនួន ៧,៨៩២.៣ លានរៀល
- ➢ កម្មវិធីទី៣៖ ការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ចំនួន ១,៨៨១.៣ លានរៀល
- ➢ កម្មវិធីទី៤៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ ចំនួន ៤៨,០៣៧.២ លានរៀល

